

# តើថ្នាំដុះធ្មេញចូលក្នុងបំពង់តាមរបៀបណា?

Let's Read

The Asia Foundation



ឆ្នាំ១៨៧០ ក្នុងទីក្រុងញូឡុងដុង រដ្ឋខននិកធីខាត់ សហរដ្ឋអាមេរិក នាម៉ោង៧ព្រឹក ក្មេងៗត្រូវបានគេដាស់ឱ្យភ្ញាក់ពីគេង។ ម្ដាយពួកគេឱ្យឈើ និងក្រឡថ្នាំដុសធ្មេញ ហើយតឿនពួកគេឱ្យទៅដុសធ្មេញ។



អីគេ? តើខ្ញុំនិយាយអី? «ឈើដុសធ្មេញ?» ត្រូវហើយ! ឈើដុសធ្មេញត្រូវបានគេប្រើប្រាស់នៅក្នុងអំឡុងឆ្នាំ១៨៧០ ។ ឈើដុសធ្មេញនោះជាឈើដែលមានចុងរសាត់រីកៗ និងសៃមម៉ៃ។ ក្មេងខ្លះមានសំណាង ក៏មានឈើដុសធ្មេញ ដែលជាសរសៃរោមជ្រូកចងភ្ជាប់នៅខាងចុង ដើម្បីជួយឱ្យធ្មេញភ្លឺ។



ហើយអីគេមួយទៀតដែលខ្ញុំបាននិយាយ? «ក្រឡថ្នាំដុសធ្មេញ?» ត្រូវហើយ! បំពង់ថ្នាំដុសធ្មេញមិនទាន់បានបង្កើតនៅឡើយទេ។ ពួកគេប្រើក្រឡ។ ហើយអ្វីដែលក្មេងៗធ្វើមុនគេជារៀងរាល់ព្រឹក គឺជ្រលក់ឈើដុសធ្មេញចូលទៅក្នុងក្រឡប៉ស៊ីឡែន ដែលដាក់ថ្នាំដុសធ្មេញ។



ជាការពិតណាស់ សមាជិកគ្រួសារទាំងអស់ធ្វើដូចគ្នា គឺជ្រលក់ឈើដុសធ្មេញទៅក្នុងដបប៉សឺឡែន។ យាយជីដូនមួយក៏ធ្វើដូចគ្នាដែរ។ គាត់មានធ្មេញពណ៌ខ្មៅហើយលឿង ដែលឈើដុសធ្មេញគាត់ក៏ត្រូវគ្នាជាមួយធ្មេញគាត់ទៀត។



ព្រឹកមួយ មានសំឡេងស្រែកបែបខ្ញើមរអើមចេញពីផ្ទះគ្រូពេទ្យធ្មេញមួយ។ «អ៊ែក...!» វាជាសំឡេងរបស់ លូស៊ីស ដែលជាកូនប្រុសរបស់ពេទ្យធ្មេញឈ្មោះ សេហ្វហ្វិល។ លូស៊ីសមិនព្រមជ្រលក់ឈើចូលក្នុងក្រឡថ្នាំដុសធ្មេញនោះទៀតទេ ហើយតាំងពីពេលនោះមកក៏សម្រេចចិត្តប្រើម្ស៉ៅថ្នាំដុសធ្មេញ។ ប៉ុន្តែលូស៊ីសតែងគិតថា វាត្រូវតែមានវិធីល្អជាងនេះក្នុងការប្រើថ្នាំដុសធ្មេញ។



ប៉ុន្មានឆ្នាំក្រោយមក លូស៊ីសបានទៅទីក្រុងប៉ារីសដើម្បីសិក្សាពីវិទ្យាទន្តសាស្ត្រ។ នៅទីនោះ គាត់បានឃើញវិចិត្រករកំពុងច្របាច់ថ្នាំពណ៌ ពីបំពង់លោហៈទៅដក់គូររូប។ ហេតុអ្វីបានជាយើងមិនប្រើថ្នាំដុសធ្មេញតាមវិធីនេះដែរទៅ? គាត់ប្រញាប់ត្រលប់ទៅផ្ទះវិញ ហើយចែករំលែកគំនិតនេះជាមួយឪពុកគាត់។ ឪពុកគាត់យល់ថា គំនិតរបស់គាត់ពិតជាអស្ចារ្យណាស់។

អ្វីដែលលំបាកនោះគឺថា តើធ្វើយ៉ាងណាដើម្បីយកថ្នាំដុសធ្មេញចេញពីក្រឡ ហើយច្រកចូលក្នុងបំពង់តាមមាត់ដ៏តូចនោះ។ តើអ្នកយល់ថា លូស៊ីសនឹងធ្វើយ៉ាងណាដើម្បីច្រកថ្នាំដុសធ្មេញចូលក្នុងបំពង់ទទេមួយបាន? តើអ្នកគិតយ៉ាងណា ប្រសិនបើអ្នកច្របាច់ថ្នាំដុសធ្មេញច្រើនពេក ទាំងអ្នកនៅមមីមមើនៅឡើយនោះ ហើយថ្នាំដុសធ្មេញនៅពាសពេញផើងលុបមុខ ហើយម្ដាយរបស់អ្នកកំពុងតឿនអ្នកថា ឡានសាលានឹងមកដល់មុខផ្ទះក្នុងពេល២០នាទី និងរឿងចុងក្រោយនោះគឺម្ដាយអ្នកនឹងខឹងយ៉ាងខ្លាំងពេលឃើញអ្នកធ្វើឱ្យប្រលាក់បែបនេះ? តើអ្នកនឹងធ្វើយ៉ាងណាដើម្បីច្រកថ្នាំដុសធ្មេញទាំងនោះចូលក្នុងបំពង់វិញ? តើអ្នកគិតថា លូស៊ីស និងឪពុកគាត់ប្រើវិធីអ្វីដើម្បីច្រកថ្នាំដុសធ្មេញចូលក្នុងបំពង់? ប្រដាប់ត្បារត្រចៀក? ឬកូនស្លាបព្រាតូចឆ្មារ? ឬឈើចាក់ធ្មេញ?



វាមិនពិបាកដូចអ្វីដែលអ្នកបានគិតទេ ព្រោះអ្វីដែលពេទ្យធ្មេញសេហ្វហ្វិល និងក្រុមរបស់គាត់បានធ្វើ គឺមិនបើកគម្របទេ។ ត្រឹមត្រូវហើយ ពួកគាត់រក្សាគម្របនៅបិទជិតដដែល ហើយបើកច្រកតាមមាត់បំពង់នៅចុងម្ខាងទៀត! វាប្រាកដជាងាយស្រួលជាង ដោយច្រកចូលបំពង់តាមច្រកមាត់ធំ ជាពិសេសបើមានអ្វីសម្រាប់ច្របាច់ថ្នាំនោះចូលបំពង់ ដូចជាស៊ីរ៉ាំងជាដើម។ ជាចុងក្រោយ អ្វីដែលយើងត្រូវធ្វើ គឺបិទមាត់នោះឱ្យជិត នោះថ្នាំដុសធ្មេញនឹងមិនចេញមកទេ។





បច្ចុប្បន្ន បំពង់ថ្នាំដុសធ្មេញត្រូវបានចាក់បំពេញដោយប្រើម៉ាស៊ីន។ បំពង់ទទេទាំងអស់ត្រូវតម្រង់ជាជួរ នៅលើខ្សែច្រវាក់ចល័តមួយ ដោយដាក់ក្បាលបំពង់បិទជិតចុះក្រោម ហើយដាក់ផ្នែកចំហឡើងលើ។ ធុងដ៏ធំមួយពេញទៅដោយថ្នាំដុសធ្មេញត្រូវបានដាក់នៅពីលើខ្សែច្រវាក់នោះ។



នៅពីក្រោមធុង ថ្នាំដុសធ្មេញត្រូវបានចាក់ឱ្យចូលក្នុងបំពង់ នៅពេលដែលបំពង់ផ្លាស់ទីតាមខ្សែច្រវាក់ចល័តនោះ។ ប៉ុន្តែ ថ្នាំដុសធ្មេញមិនត្រូវបានបំពេញឱ្យពេញនោះទេ។ ចន្លោះប្រហែលមួយសង់ទីម៉ែត្រ ត្រូវបានទុកដើម្បីបិទគម្រប។ ពេលនេះបំពង់រួចរាល់សម្រាប់បិទហើយ។



វិធីបុរាណរបស់ជនជាតិឥណ្ឌា ដើម្បីធ្វើឱ្យធ្មេញស្អាត មនុស្សជាច្រើនបានប្រើដាទុន មែកនីម ឬដើមបាប៊ូលជំនួសឱ្យច្រាសដុសដែលផលិតដោយរោងចក្រ។ ដាទុនធ្វើឱ្យធ្មេញ និងអញ្ចាញមានសុខភាពល្អ។ ប៉ុន្តែ តើអ្នកដឹងទេថា ច្រាសដុសធ្មេញអ្វីដែលល្អបំផុត? នោះគឺចង្អុលដៃរបស់អ្នក នេះបើតាមយោបល់របស់ទន្តបណ្ឌិត។ វាល្អបំផុតសម្រាប់ធ្មេញ និងអញ្ចាញ។ ចុះអ្នកធ្លាប់ប្រើម្សៅដុសធ្មេញទេ? តើអ្នកបានសង្កេតដឹងក្លិនអ្វីដែលភ្ជាប់ជាមួយម្សៅនោះទេ? ឱសថ និងគ្រឿងទេសដែលល្អសម្រាប់ធ្មេញ មានជីអង្កាម ផ្កាក្លូវ ឈើអែម ម្រេចខ្មៅ និងម្រះព្រៅ។ ការបរិភោគផ្លែឈើដែលមានជាតិសរសៃច្រើន

និងបន្លែ ដូចជាផ្លែប៉ោម និងការ៉ុត គឺល្អណាស់សម្រាប់សម្អាតធ្មេញ។



លេងសប្បាយជាមួយគម្របថ្នាំដុសធ្មេញ

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*How Does the Toothpaste Get into the Tube?*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Sovannaroath Tang and Sodany Ouch